**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៩៧ សសរ**

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៤ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- យោងតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហៅកាត់ថា "គ.ស.ហ" ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ជា ចាន់តូ** | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |

| | | |
|---|---|---|
| ២- លោកជំទាវ **ខូន សុខា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ទ្រី ត្រាយ** | អនុប្រធានលេខាធិការដ្ឋាន គជបក | អនុប្រធាន |
| ៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឌី ទិដ្ឋា** | សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៥- ឯកឧត្តម **មុី ម៉ាន់** | សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **ម៉ែន ពេជ្រសាលី** | សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៧- ឯកឧត្តម **ភីម វត្តទិសិដ្ឋ** | សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម **ចាយ ណារុធ** | អនុរដ្ឋលេខាធិការ តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩- លោកជំទាវ **សាយ សំអាត** | អគ្គលេខាធិការអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិកា |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ